https://khmer.cambojanews.com/four-thai-citizens-arrested-in-cambodia-over-links-to-online-scam-and-triple-murder/ Go
1 capture
27 Sep 2023
AUG SEP OCT
27
2022 2023 2024
About this capture



ព័ត៌មានជាតិ, សង្គម

# ចាប់ខ្លួនជនជាតិថៃបួននាក់នៅកម្ពុជាពាក់ព័ន្ធនឹងអំពើឆបោកតាមអនឡាញ និងឃាតកម្មលើមនុស្សបីនាក់

១៤ កញ្ញា ២០២៣ ម៉ោង ១១:២៩ | វ៉ាន់ ស្រីដែត




*សមត្ថកិច្ចកម្ពុជាចាប់ខ្លួនជនជាតិថៃបួនរូបនៅក្រុងប៉ោយប៉ែតរងការចោទប្រកាន់ថាជាប់ពាក់ព័ន្ធនឹងអំពើឆបោកតាមអនឡាញ និងឃាតកម្មលើមនុស្សបីនាក់។ រូបភាពផ្សាយលើគេហទំព័រអគ្គស្នងការដ្ឋាននគរបាលជាតិ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣។*

ជនជាតិថៃបួនរូបដែលរងការចោទប្រកាន់ថាបានជាប់ពាក់ព័ន្ធនឹងប្រតិបត្តិការឆបោកតាមអនឡាញ និងឃាតកម្មលើមនុស្សបីនាក់ ត្រូវបានចាប់ខ្លួននៅក្រុងប៉ោយប៉ែតកាលពីចុងសប្តាហ៍នេះ។

បើតាមកាសែតបាងកកប៉ុស្តិ៍ ជនសង្ស័យមានឈ្មោះ Supol Wongwian, Nisarat Sukasem, Kanokporn

Kraisuk និង Kornkanok Singthit ប្រឈមមុខនឹងការចោទប្រកាន់ពីបទសមគំនិតក្នុងអំពើឆបោក ឧក្រិដ្ឋកម្មអនឡាញ និងបានចូលរួមជាមួយក្រុមឧក្រិដ្ឋកម្មឆ្លងដែន។

លោក កែវ វណ្ណថន អ្នកនាំពាក្យនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ បញ្ជាក់ថាជនសង្ស័យទាំងបួនរូបកំពុងឃុំខ្លួននៅអគ្គស្នងការដ្ឋាននគរបាលជាតិ។ លោកថា នាយកដ្ឋានរបស់លោកកំពុងរង់ចាំការសម្រេចរបស់ក្រសួងមហាផ្ទៃលើសំណើបញ្ជូនអ្នកទាំងនោះទៅប្រទេសថៃវិញ ហើយថាលោកមិនអាចបញ្ជាក់កាលបរិច្ឆេទនៃការបញ្ជូនអ្នកទាំងនោះបានទេ។

អគ្គស្នងការនគរបាលជាតិកម្ពុជាបានធ្វើការរួមគ្នាជាមួយនគរបាលភូមិន្ទថៃលើការស៊ើបអង្កេត និងឈានទៅដល់ការកំណត់អត្តសញ្ញាណ និងចាប់ខ្លួនជនសង្ស័យ។

បើតាមអគ្គស្នងការនគរបាលជាតិ ជនសង្ស័យដែលបានចាប់ខ្លួននេះមានជាប់ពាក់ព័ន្ធនឹងប្រតិបត្តិការឆបោកតាមអនឡាញ ដែលអំពើនេះបានជំរុញឲ្យបុរសជនជាតិថៃម្នាក់ប្រព្រឹត្តអំពើឃាតកម្មលើសមាជិកគ្រួសាររបស់ខ្លួន។ លោក Sanit Dokmai វ័យ៤១ឆ្នាំ ជាប់ចោទពីបទឃាតកម្មលើប្រពន្ធ និងកូនពីរនាក់របស់ខ្លួន មុនពេលលោកព្យាយាមធ្វើអត្តឃាតតាមក្រោយ បន្ទាប់ពីលោកបាញ់បោកគេអស់ប្រាក់ ៤៧ ០០០ដុល្លារ និងធ្វើឲ្យគ្រួសារជាប់បំណុល។

បើតាមការផ្សាយរបស់សារព័ត៌មាន Thai PBS World កាលពីសប្តាហ៍មុនអគ្គស្នងការនគរបាលជាតិកម្ពុជា លោក ស ថេត និងអគ្គស្នងការរងនគរបាលភូមិន្ទថៃលោក Surachate Hakparn បានពិភាក្សាគ្នាលើការពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកនគរបាលរវាងប្រទេសទាំងពីរ។ លោក Hakparn ក៏បានស្វែងរកកិច្ចសហការចាប់ខ្លួនជនសង្ស័យជនជាតិថៃ និងចិន ដែលជាប់ពាក់ព័ន្ធនឹងប្រតិបត្តិការឆបោកតាមអនឡាញ ដែលជាប់ពាក់ព័ន្ធនឹងឃាតកម្មលើមនុស្សបីនាក់ផងដែរ។

អ្នកនាំពាក្យក្រសួងមហាផ្ទៃ លោក ខៀវ សុភ័គ មានប្រសាសន៍ថា ការចាប់ខ្លួននេះជាលទ្ធផលនៃការចូលរួមសហការគ្នាជាមួយនគរបាលថៃ ហើយលោកបានបន្ថែមថារដ្ឋាភិបាលកម្ពុជា ***«បានធ្វើការជាច្រើន»*** ក្នុងការបង្ក្រាបអំពើឆបោកទាំងនេះ។

លោកបន្តថា៖ *«ពួកគេ [ប្រព័ន្ធផ្សព្វផ្សាយ]ថាយើងមានមនុស្ស ២ ០០០នាក់ ឥឡូវពួកគេថាយើងមានមនុស្ស ១០០ ០០០នាក់ ស្រេចតែពួកគេថា យើងបានបន្ត [បង្ក្រាប] សម្រាប់ប្រទេសជាតិយើង»*។ ការលើកឡើងរបស់លោក ខៀវ សុភ័គ ទំនងសំដៅដល់របាយការណ៍របស់អង្គការសហប្រជាជាតិចេញផ្សាយថ្មីៗនេះថាមានជនរងគ្រោះពីអំពើឆបោកនៅកម្ពុជា ១០០ ០០០នាក់។

ថ្វីបើមានសេចក្តីរាយការណ៍ជាច្រើនលើកថាប្រតិបត្តិការអំពើឆបោកក្នុងប្រទេសកម្ពុជាមានជាប់ពាក់ព័ន្ធនឹងអ្នកជំនួយ និងអ្នកនយោបាយមានឥទ្ធិពលនៅកម្ពុជា លោក សុភ័គ អះអាងថាប្រជាជនកម្ពុជាមិនប្រព្រឹត្តឧក្រិដ្ឋកម្មបែបនេះទេ។

លោក ខៀវ សុភ័គ បន្ថែមថា៖ ***«ប្រជាពលរដ្ឋកម្ពុជាមិនប្រព្រឹត្តឧក្រិដ្ឋកម្មបែបនេះទេពីព្រោះថាប្រជាពលរដ្ឋខ្មែរមិនមានចំណេះដឹងក្នុងការប្រើប្រាស់កុំព្យូទ័រសម្រាប់អំពើឆបោកតាមអនឡាញទេ។ មានជនបរទេសដែលប្រើ[កម្ពុជា] ជាទីតាំងប្រព្រឹត្តបទល្មើស»***។

ក្នុងរបាយការណ៍របស់ខ្លួនចេញផ្សាយកាលពីខែសីហា អង្គការសហប្រជាជាតិបានបង្ហាញថាកម្ពុជាបានប្រែពីប្រទេសដែលមានជនរងគ្រោះនៃអំពើជួញដូរ មកជាប្រទេសគោលដៅដែលជនរងគ្រោះបរទេសត្រូវគេជួយដូរចូលមកវិញ និងបានបង្ហាញទៀតថាទីតាំងជាច្រើននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលមានការបង្ខំមនុស្សឲ្យប្រព្រឹត្តអំពើឆបោកតាមអនឡាញ គឺ

ជាតំបន់ដែលមានការគ្រប់គ្រងខ្សោយ និងនីតិរដ្ឋខ្សោយ។

មន្ត្រីកម្ពុជាម្តងហើយម្តងទៀតបានប្រានចោលថាបុគ្គលិកទាំងនោះជាជនរងគ្រោះនៃការធ្វើការដោយបង្ខំ បន្ទាប់ពីអ្នកទាំងនោះត្រូវបានសមត្ថកិច្ចជួយឲ្យបានរួចខ្លួនពីកន្លែងធ្វើការទាំងនោះ។

លោកស្រី ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៃក្រសួងមហាផ្ទៃ និងលោក ឆាយ គីមខឿន អ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិបដិសេធអត្ថាធិប្បាយលើរឿងនេះ។

ស្នងការនគរបាលខេត្តបន្ទាយមានជ័យលោក សិទ្ធិ ឡោះ មិនអាចទាក់ទងសុំការអត្ថាធិប្បាយបានទេ។ ចំណែកស្ថានទូតថៃប្រចាំទីក្រុងភ្នំពេញក៏មិនបានឆ្លើយតបនឹងសំណើសុំអត្ថាធិប្បាយនេះដែរ។

លោក ស៊ុំ ចាន់គា មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុកប្រចាំខេត្តបន្ទាយមានជ័យមានប្រសាសន៍ថាប្រទេសកំពុងអភិវឌ្ឍន៍ដូចកម្ពុជាបានក្លាយជាកន្លែងលាក់ខ្លួនរបស់ពួកឆបោកមកពីប្រទេសផ្សេងៗ។

លោក ចាន់គា បន្តថា រដ្ឋាភិបាលគួរតែប្រើលទ្ធភាពរបស់ខ្លួនក្នុងការបិទខ្ទប់វែបសាយទាំងនោះដើម្បីការពារអំពើឆបោកតាមអនឡាញ ហើយថាការមានករណីបែបនេះញឹកញាប់អាចនាំឲ្យចំនួនភ្ញៀវទេសចរពីប្រទេសជិតខាងធ្លាក់ចុះ និងអាចប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជា។

លោកបន្ថែមថា៖ *«វាជាការសំខាន់ណាស់ដែលរដ្ឋាភិបាលថ្មីត្រូវយកចិត្តទុកដាក់លើបញ្ហាទាំងនេះ ពីព្រោះបើសិនជានៅពន្យារពេល វានឹងបន្តកើតមានឡើង ហើយធ្វើឲ្យកម្ពុជាក្លាយជាកន្លែងសម្រាប់ឧស្សាហកម្មជួញដូរមនុស្ស និងឆបោកតាមអនឡាញ»*៕

***រាយការណ៍បន្ថែមដោយ យួន ណារីម***

ប្រែសម្រួលពីអត្ថបទភាសាអង់គ្លេស៖ Four Thai Citizens Arrested in Cambodia Over Links to Online Scam and Triple Murder

174 views

កម្ពុជា, ឃាតកម្ម, ចាប់ខ្លួន, ចោទប្រកាន់, ជនជាតិថៃ, ប៉ោយប៉ែត, អនឡាញ, អំពើឆបោក

## ព័ត៌មានថ្មីៗ

សាលាអូរ១៧ក្នុងស្រុកវាលវែង ត្រូវការអគារសិក្សាថ្មី ខណៈគ្រូៗបារម្ភពីសិស្សមួយចំនួនឈប់រៀនទាំងវ័យក្មេង
២៥ កញ្ញា ២០២៣

តុលាការផ្តន្ទាទោសមន្ត្រីជាន់ខ្ពស់គណបក្សភ្លើងទៀន លោក ថាច់ សេដ្ឋា ដាក់ពន្ធនាគារចំនួន១៨ខែ
២១ កញ្ញា ២០២៣

ជនជាតិដើមភាគតិចនៅក្នុងភូមិមួយនៃខេត្តរតនគិរី កាប់ឈើទាំងប្រឈមគ្រោះថ្នាក់ដើម្បីយកលុយសងបំណុល
២១ កញ្ញា ២០២៣

VOD នឹងផ្សាយឡើងវិញពីសហរដ្ឋអាមេរិក បន្ទាប់ពីរដ្ឋាភិបាលកម្ពុជាបានបិទកាលពីដើមឆ្នាំនេះ
២០ កញ្ញា ២០២៣

## អត្ថបទពេញនិយម

1 មនុស្ស១០នាក់បានស្លាប់នៅចម្ការចេកមួយកន្លែងក្នុងខេត្ត...

2 ជនជាតិដើមភាគតិចក្តួយដាក់បណ្តឹងសាមន្ត្រីបរិស្ថានដែលសាង...

3 នីតិវិធីថ្មីអាចរារាំងគណបក្សភ្លើងទៀនមិនឲ្យចុះឈ្មោះបោះ...

4 ការគំរាមកំហែង ការបំផ្លិចបំផ្លាញ និងការលក់ដីដោយបង្ខំ...

5 VOD នឹងផ្សាយឡើងវិញពីសហរដ្ឋអាមេរិក...


### សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា

(+៨៥៥)២៣ ៨៨ ២៣ ១១

editor@cambojanews.com

ផ្ទះលេខ១៩ ផ្លូវ៣៨៨ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌបឹងកេងកង